**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**
**លេខ** :.................០០៤/១៧..........ក.ប/ស.ណ.ន.ក.ប.អ

# សេចក្តីណែនាំ
# ស្តីពី
# ការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់នៅតាមសហគ្រាស គ្រឹះស្ថាន

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមជម្រាបជូនដល់និយោជក សមាគមនិយោជក កម្មករនិយោជិត សហជីព និងប្រតិភូបុគ្គលិកនៃសហគ្រាស គ្រឹះស្ថានទាំងអស់បានជ្រាបថា ដើម្បីប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់នៅតាមសហគ្រាស គ្រឹះស្ថានឱ្យមានប្រសិទ្ធភាពខ្ពស់ ជាពិសេសចូលរួមអនុវត្តផែនការរបស់រាជរដ្ឋាភិបាលកម្ពុជាលេខ០១ផ.ក ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១៦ ស្តីពីយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់លើកទី១ រយៈពេល៦ខែ(ចាប់ពីថ្ងៃទី០១ ខែមករា ដល់ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៧) ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមធ្វើការណែនាំដល់ និយោជក សមាគមនិយោជក កម្មករនិយោជិត សហជីពនិងប្រតិភូបុគ្គលិកនៃសហគ្រាស គ្រឹះស្ថានទាំងអស់ត្រូវចូលរួមអនុវត្ត និងបំពេញភារកិច្ចដូចខាងក្រោម៖

១-និយោជកនៃសហគ្រាស គ្រឹះស្ថាន ត្រូវសហការជាមួយកម្មករនិយោជិត សហជីព និងប្រតិភូបុគ្គលិក ដើម្បីរៀបចំផែនការបង្ការ ទប់ស្កាត់កុំឱ្យមានការប្រើប្រាស់ និងជួញដូរគ្រឿងញៀននៅតាមសហគ្រាស គ្រឹះស្ថាន។

២-ត្រូវបានប្រគល់ភារកិច្ចបន្ថែមដល់ក្រុមការងារអេដស៍ ឬគណៈកម្មការអេដស៍ឱ្យអនុវត្តភារកិច្ចប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់នៅតាមសហគ្រាស គ្រឹះស្ថាន។ សហគ្រាស គ្រឹះស្ថានណាដែលមិនទាន់មានក្រុមការងារអេដស៍ ឬគណៈកម្មការអេដស៍ត្រូវរៀបចំបង្កើតយន្តការនេះឱ្យបានឆាប់។ ក្រុមអធិការកិច្ចការងារ និងមន្ទីរការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានី-ខេត្ត ត្រូវជួយដល់សហគ្រាស គ្រឹះស្ថានក្នុងការអនុវត្តការងារនេះ។

៣-ត្រូវបន្ថែមសមាសភាពទៅក្នុងក្រុមការងារអេដស៍ ឬគណៈកម្មការអេដស៍នូវសមាសភាពមកពីតំណាងសហជីព ប្រតិភូបុគ្គលិក ឬតំណាងកម្មករនិយោជិត។

៤-ក្រៅពីការបំពេញតួនាទីភារកិច្ចរបស់ខ្លួនដូចមានចែងក្នុងតួនាទីភារកិច្ច របស់ក្រុមការងារអេដស៍ ឬគណៈកម្មការអេដស៍ ហើយត្រូវបំពេញបន្ថែមនូវតួនាទីភារកិច្ចដូចខាងក្រោម៖

- រៀបចំនិងចាត់ចែងអនុវត្តផែនការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់នៅតាមសហគ្រាស។



អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣) ៨៨ ៤៣ ៧៥ និងទូរសារ :(០២៣)៨៨ ២៧ ៦៩

- គ្រឹះស្ថានអប់រំផ្សព្វផ្សាយដល់និយោជក មេការ ប្រធានផ្នែកនានា ថ្នាក់ដឹកនាំសហជីព ប្រតិភូបុគ្គលិក និងធ្វើការអប់រំផ្សព្វផ្សាយដល់កម្មករនិយោជិតនៅក្នុងសហគ្រាសគ្រឹះស្ថានរបស់ខ្លួន។
- លើកសំណើទៅក្រុមអធិការកិច្ចការងារ មន្ទីរការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានី-ខេត្ត និងលេខាធិការដ្ឋានអេដស៍ និងគ្រឿងញៀននៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ឬអាជ្ញាធរមានសមត្ថកិច្ច ក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធ ដើម្បីសុំជំនួយបច្ចេកទេសសម្រាប់អនុវត្តភារកិច្ចរបស់ខ្លួនឱ្យមានប្រសិទ្ធភាព។
- ធ្វើការប្រជុំជាទៀងទាត់ ១ខែ ម្តង ដើម្បីបូកសរុបការងារ និងលើកទិសដៅបន្ត។
- ធ្វើរបាយការណ៍ប្រចាំខែ ឬតាមពេលវេលាចាំបាច់ទៅមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានី-ខេត្តនិងលេខាធិការដ្ឋានអេដស៍ និងគ្រឿងញៀននៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

៥-ក្នុងករណីពិនិត្យ និងរកឃើញថា មានកម្មករនិយោជិតណាប្រើប្រាស់គ្រឿងញៀន នៅក្នុងសហគ្រាស គ្រឹះស្ថាន និយោជក សហជីព និងប្រតិភូបុគ្គលិក ឬតំណាងកម្មករនិយោជិត ត្រូវពិគ្រោះយោបល់គ្នា អំពីស្ថានភាពជាក់ស្តែង ដើម្បីជួយសម្រួលឱ្យទៅទទួលសេវាព្យាបាល និងស្តារនីតិសម្បទារបស់រដ្ឋ ឬឯកជន ដោយគ្មានការរើសអើង។

-ក្នុងករណីមានការជួញដូរគ្រឿងញៀនខុសច្បាប់ត្រូវចាត់ទុកជាកំហុសធ្ងន់ និងត្រូវចាត់វិធានការតាមច្បាប់ស្តីពីការងារ និងត្រូវរាយការណ៍ជាបន្ទាន់ទៅអាជ្ញាធរមានសមត្ថកិច្ច។

៦-គ្រប់សហគ្រាសគ្រឹះស្ថានត្រូវរៀបចំដាក់បដាពាក្យស្លោកជាអាទិ៍៖

- សហគ្រាស គ្រឹះស្ថានស្អាតស្អំគ្មានគ្រឿងញៀន
- កម្មករនិយោជិត និងនិយោជករួមគ្នាប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់
- និយាយថា ទេ ចំពោះគ្រឿងញៀន
- គ្រឿងញៀនបំផ្លាញជីវិតយើង គ្រួសារយើង និងសហគ្រាសគ្រឹះស្ថានយើង

៧-គណៈកម្មការសម្របសម្រួលត្រីភាគីប្រយុទ្ធនឹងជំងឺអេដស៍ និងគ្រឿងញៀននៅកន្លែងធ្វើការនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវត្រួតពិនិត្យ វាយតម្លៃ និងលើកសរសើរដល់អង្គភាព ឬបុគ្គលណា ដែលមានស្នាដៃក្នុងការអនុវត្តការងារនេះ។

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មានសេចក្តីសង្ឃឹមយ៉ាងមុតមាំថា និយោជក សហជីព កម្មករនិយោជិត ក្រុមការងារអេដស៍ ឬគណៈកម្មការអេដស៍ទាំងអស់នឹងចូលរួមអនុវត្តតាមសេចក្តីណែនាំនេះបានល្អប្រសើរប្រកបដោយប្រសិទ្ធភាពខ្ពស់។

រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ២០១៧

**រដ្ឋមន្ត្រី**

**អ៊ិត សំហេង**